**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៦៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត "**សាលាជាតិរដ្ឋបាលមូលដ្ឋាន**" ដែលសរសេរជាអក្សរកាត់ថា "**ស.ជ.រ.ម**" និងមានឈ្មោះជាភាសាអង់គ្លេសថា National School of Local Administration ដែលសរសេរជាអក្សរកាត់ថា "NASLA"។

**មាត្រា២.-**

សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវស្ថិតនៅក្រោមឱវាទរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៣.-**

សាលាជាតិរដ្ឋបាលមូលដ្ឋានមានតួនាទីអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ សិស្ស និស្សិត និងអ្នកពាក់ព័ន្ធដទៃទៀត ព្រមទាំងសិក្សាស្រាវជ្រាវអំពីអភិបាលកិច្ចការអភិវឌ្ឍមូលដ្ឋាន ការលើកកម្ពស់ស្វ័យភាពមូលដ្ឋាន និងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៤.-**

សាលាជាតិរដ្ឋបាលមូលដ្ឋានមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលមធ្យម រយៈពេលវែង និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
- រៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សា
- ផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យម
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាដល់សិក្ខាកាម
- សិក្សាស្រាវជ្រាវ និងផ្តល់យោបល់លើការរៀបចំតាក់តែងនិងអនុវត្តគោលនយោបាយនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- អនុវត្តកិច្ចការផ្សេងៗទៀតតាមការចាំបាច់។

**មាត្រា៥.-**

សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពមកពីក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីផ្តល់យោបល់ និងពិនិត្យសម្រេចលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីសិក្សា និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាភិបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

សមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៦.-**

សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវដឹកនាំដោយនាយកមួយ(០១)រូប ដែលមានឋានៈស្មើអគ្គនាយករង

និងនាយករងមួយចំនួនដែលមានឋានៈស្មើប្រធាននាយកដ្ឋាន ដោយអនុលោមតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**មាត្រា៧**.-

សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវមានទីចាត់ការមួយចំនួនតាមការចាំបាច់។

ទីចាត់ការនីមួយៗត្រូវមាននាយកទីចាត់ការមួយ(០១)រូបដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងទីចាត់ការមួយចំនួនជាជំនួយការដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ទីចាត់ការចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៨**.-

សាលាជាតិរដ្ឋបាលមូលដ្ឋាន ដោយមានកិច្ចសហការ និងសម្របសម្រួលជាមួយនាយកដ្ឋានបណ្តុះបណ្តាលនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រ កម្មវិធីសិក្សា ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងសម្ភារឧបទេសផ្សេងៗទៀតតាមការចាំបាច់។

**មាត្រា៩**.-

សាលាជាតិរដ្ឋបាលមូលដ្ឋានមានសិទ្ធិសហការជាមួយសាកលវិទ្យាល័យ វិទ្យាស្ថាន សាលាបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស និងអ្នកពាក់ព័ន្ធនានាដើម្បីអនុវត្តផែនការយុទ្ធសាស្ត្ររបស់ខ្លួនតាមការចាំបាច់។

**មាត្រា១០**.-

សាលាជាតិរដ្ឋបាលមូលដ្ឋានមានប្រភពធនធានដូចខាងក្រោមៈ

- ថវិកាជាតិដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងមហាផ្ទៃ
- ថវិកាដែលទទួលបានពីការបង់ថ្លៃបណ្តុះបណ្តាល
- ប្រភពផ្សេងទៀត។

សាលាជាតិរដ្ឋបាលមូលដ្ឋានមានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារផ្សេងៗទៀតពីប្រភពខាងក្នុង ឬ ក្រៅប្រទេសសម្រាប់បម្រើសេចក្តីត្រូវការរបស់ខ្លួន ដោយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

**មាត្រា១១**.-

ក្នុងដំណាក់កាលដែលសាលាជាតិរដ្ឋបាលមូលដ្ឋានពុំទាន់ដំណើរការ នាយកដ្ឋានបណ្តុះបណ្តាលនៃអគ្គនាយកដ្ឋានរដ្ឋបាលមានតួនាទីជាសេនាធិការជូនក្រុមប្រឹក្សាភិបាល និងក្រសួងមហាផ្ទៃនៅក្នុងកិច្ចដំណើរការរៀបចំបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន។

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*